# រឿង ខ្លាស៊ីកូនតាពស់ព្រៃ

---

ក្នុងកាលកន្លងយូរអង្វែងទៅហើយ មានបុរសម្នាក់ជាចាស់ព្រឹទ្ធាចារ្យឈ្មោះតាពស់ព្រៃ គាត់ជាមនុស្សទីទ័លក្រ បានមកតាំងទីលំនៅ ធ្វើស្រែចម្ការ នៅក្បែរជើងភ្នំតែពីរនាក់ប្ដីប្រពន្ធ ។ លុះនៅយូរៗ ទៅបានកូនប្រុសម្នាក់ គាត់ចិញ្ចឹមបីបាច់តាំងពីតូចរហូតដល់បានអាយុ ១ឆ្នាំ បានប្រកបដោយសេចក្ដីសុខដរាបរៀងមក ឥតដែលមានមោះហ្មងអ្វីឡើយ ។ ថ្ងៃមួយ តាពស់ព្រៃនិងប្រពន្ធ កាលបើបញ្ចុកអាហារឲ្យកូនបរិភោគរួចក៏ផ្ដេកកូននោះនៅក្នុងរោងជាលំនៅរបស់គាត់ ដូចកាលសព្វដងរៀងមក មិនបានគិតក្រែងមានគ្រោះថ្នាក់ដល់កូនសោះទេ ហើយយកដងរែកសង្រែក និងកណ្ដៀវចេញទៅតាំងពីព្រលឹមរហូតដល់ថ្ងៃត្រង់ ចោលកូនឲ្យដេកនៅក្នុងរោងតែម្នាក់ឯង ។ ក្រោយពីតានិងយាយចេញផុតទៅ មានខ្លាធំ ១ ដែលបិតនៅក្នុងព្រៃជិតនោះ លបចូលទៅក្នុងរោង ឃើញទារកដេកតែម្នាក់ឯង ក៏ពាំយកទារកនោះទៅស៊ីជាអាហារ ។ កុមារនោះ ពុំបានស្រែកយំមួយម៉ាណាសោះ ដោយវានៅតូចដេកពុំដឹងខ្លួន ។ ឯតាពស់ព្រៃនិងយាយជាភរិយា ខំច្រូតស្រូវនៅក្រោមកម្ដៅព្រះអាទិត្យ តាំងពីព្រឹកពុំហ៊ានឈប់សម្រាកសោះ ។ លុះថ្ងៃត្រង់ អត់ទ្រាំនឹងកម្ដៅព្រះអាទិត្យទៅទៀតពុំបាន ។ គាត់ក៏រៀបកណ្ដាប់ស្រូវដាក់ក្នុងសង្រែក និងចងជាទ្រនូល ហើយតាពស់ព្រៃលើកអម្រែកដាក់លើស្មា ដើរតាមក្រោយយាយ ទូលកណ្ដាប់ស្រូវ យាត្រារលះរលាំងសំដៅទៅកាន់ទីលំនៅរបស់ខ្លួន ។ ទៅដល់លំនៅហើយ ក៏ដាក់អម្រែកនិងទ្រនូល ក្រឡេកមើលទៅក្នុងរោងមិនឃើញកូនរបស់ខ្លួនដែលផ្ដេកនោះ គាត់មានសេចក្ដីតក់ស្លុតញាប់ញ័រក្នុងចិត្តជាខ្លាំង ទាំងពីរនាក់ប្ដីប្រពន្ធគយគន់រំពៃ ក្បែរៗកន្លែងកូនដេកនោះ ឃើញមានតែដានជើងខ្លាមួយយ៉ាងធំ និងស្នាមឈាមស្រក់ តាំងពីកន្លែងកូនដេក រហូតដល់ព្រៃលំ ។ តាពស់ព្រៃនិងភរិយា បានដឹងច្បាស់ថា ខ្លាពាំយកកូនទៅស៊ីជាអាហារ ហើយក៏យំសោកសង្រេងសង្រែ អាល័យអាណិតអាសូរដល់កូនតូចដែលមិនដឹងអ្វី តាំងពីកណ្ដាលថ្ងៃត្រង់ រហូតដល់ពេលយប់ ទើបតាពស់ព្រៃនិងភរិយា ឈប់សោយសោក ហើយងាកមកពិចារណាថា : បើយើងគិតតែយំសោកអាឡោះអាល័យ បោកខ្លួនដូច្នេះតទៅទៀត ឃើញថា ឥតបានប្រយោជន៍អ្វីបន្តិចបន្តួចសោះ ដូច្នេះគួរគប្បីយើងយំស្រែក ហើយគិតរកមធ្យោបាយដូចម្ដេចនឹងសម្លាប់ខ្លានេះឲ្យខាងតែបាន ។ លុះព្រឹកឡើង ក៏បានសម្រេចចិត្តថា ត្រូវតែតាមរកសម្លាប់ខ្លាដែលស៊ីកូនខ្លួននោះ ឲ្យខាងតែបាន ។ ចាប់ដើមពីនោះមក រាល់ព្រឹកភរិយាក្រោកពីព្រលឹម រៀបចំម្ហូបអាហារ បាយសំណុំទឹកបំពង់ និងបៀកស្លាដាក់ក្នុងសំពៀតជូនស្វាមីរៀងរាល់ថ្ងៃ ដើម្បីដើរតាមរកសម្លាប់ខ្លាសាហាវដែលបានមកបំផ្លាញជីវិតកូននោះ ។

រីឯតាពស់ព្រៃ កាលប្រពន្ធរៀបចំបាយកញ្ចប់ ស្លា ដាក់សំពៀតរួចហើយ ក៏ធ្វើដំណើរចូលទៅក្នុងព្រៃ ស្មាម្ខាងស្ពាយបាយនិងសំពៀតស្លា ស្មាម្ខាងទៀត លីពូថៅ ដើរយ៉ាងអង់អាចចូលទៅក្នុងព្រៃភ្នំ រុកតត្រុករកខ្លាតាំងពីជើងភ្នំរហូតដល់កំពូល មើលសព្វជ្រោះជ្រលង រូងថ្មតូច-ធំ ឆ្លងព្រៃកាត់វាល ឆ្លងវាលចូលព្រៃ រៀងរាល់ថ្ងៃ ។ គាត់ដើរតាមរកខ្លានោះតាំងពីខែប្រាំងរហូតដល់ខែវស្សា មានទឹកជំនន់ជន់លិចស្រែចម្ការលិចព្រៃព្រឹក្សាលតាវល្លិរហូតដល់ជើងភ្នំ បណ្ដាលឲ្យសត្វទាំងឡាយ ដែលអាស្រ័យនៅក្នុងព្រៃនោះទាំងប៉ុន្មាន ផ្អើលរត់ឡើងទៅពឹងពាក់អាស្រ័យនៅលើកំពូលភ្នំទាំងអស់

ដោយខ្លាចក្រែងទឹកជន់លង់ស្លាប់ ។ ថ្ងៃមួយតាពស់ព្រៃ ដើរទៅប្រទះនឹងខ្លា ដែលខាំកូនរបស់គាត់នោះ គាត់ក៏គិតថា ពិតជាខ្លានេះហើយដែលចូលទៅខាំកូនអញស៊ី ព្រោះដានជើងដែលអញបានឃើញ និងជើងខ្លានេះមានទំហំប៉ុនគ្នា ហើយមិនឃើញមានខ្លាដទៃណាធំដូចខ្លានេះផង មានតែខ្លានេះហើយ ជាមេហ្វូងធំជាងគេ បានជាហ៊ានចូលទៅខាំកូនអញស៊ីទាំងថ្ងៃដូច្នេះ ។ តាពស់ព្រៃគិតថា បើអញសម្លាប់ខ្លានេះដោយកម្លាំងបាយ មុខជាមិនឈ្នះវាទេ គួរគប្បីអញប្រើគំនិតនិងប្រាជ្ញា ដើម្បីសម្លាប់ខ្លានេះ ទើបបាន ។ គិតស្រេចទើបតាពស់ព្រៃបញ្ចេញវាចាយ៉ាងខ្លាំង ៗ ដើម្បីឲ្យឮទៅដល់ខ្លាថា: "វល្លិណាតូច ៗ ចងឆ្នាំងចងអំបែង វល្លិណាវែង ៗ ចងកូនចងចៅ ចងញាតិសន្តានព្យួរលើចុងឈើ " ។ មាត់តែថា ភ្នែកតែរំពៃមើលលើមើលក្រោម មើលឆ្វេង-មើលស្តាំ, ដៃស្តាំកាន់ពូថៅ ដៃឆ្វេងទាញវល្លិ ធ្វើឫកពា ហាក់ដូចជាអ្នករកវល្លិមែន ៗ លុះទន្ទេញដូន ៗ ឮទៅដល់ខ្លា ។ ខ្លាមានសេចក្តីសង្ស័យក៏សួរទៅតាពស់ព្រៃថា: តា ៗ បោចវល្លិយកទៅចងអី ? តាពស់ព្រៃប្រាប់ទៅខ្លាវិញថា: " អញបោចវល្លិយកទៅ ចងឆ្នាំចងអំបែង ចងកូនចងចៅ ចងញាតិសន្តានរបស់អញ ព្យួរលើចុងឈើ ព្រោះនៅតែ ៧ ថ្ងៃទៀត នឹងមានទឹកជំនន់ជន់លិចស្រែចម្ការ លិចព្រៃព្រឹក្សា លិចទាំងបព្វតា ស្លាប់មនុស្សនឹងអាខ្លាឯងនេះអស់ហើយ " ។ រីឯសត្វខ្លាឮតាពស់ព្រៃ ប្រាប់ដូច្នោះ មានចិត្តភិតភ័យនឹងសេចក្តីស្លាប់ពន់ពេក ក៏និយាយសុំឲ្យតាចង ខ្លួនព្យួរទៅលើចុងឈើផង ។ តាពស់ព្រៃប្រកែកថា " អញមិនរវល់ចងអាខ្លាឯងព្យួរលើចុងឈើទេ ទុកឲ្យអាខ្លាឯងលង់ទឹកស្លាប់ទៅចុះ បើអាខ្លាឯងមិនជឿអញទេ ឯងទៅឡើងលើថ្មដាណាដែលខ្ពស់ជាងគេ ហើយក្រឡេកមើលទៅជុំវិញភ្នំ គង់នឹងឃើញទឹកដែលកំពុងជន់ច្រើនឡើងមិនខាន"។ខ្លាឮតាពស់ព្រៃប្រាប់ដូច្នោះ ក៏ខំរត់ទៅរកថ្មដាដែលខ្ពស់ជាងគេលើកំពូលភ្នំ ហើយឈរមើលទៅជុំវិញភ្នំ ឃើញទឹកល្អល្អាច ដូចតាពស់ព្រៃប្រាប់មែន ។ ខ្លាភ័យតក់ស្លុតខ្លាំងណាស់ រត់ចុះមករកតាពស់ព្រៃវិញ ហើយអង្វរតាហើយអង្វរទៀត សុំឲ្យតាចងព្យួរខ្លួនទៅលើចុងឈើ តាពស់ព្រៃរឹតតែបានចិត្តហើយពោលថា: " អញព្រមចងអាខ្លាឯងដែរ តែអញចងតែវល្លិណាតូច ៗ ឲ្យដាច់ធ្លាក់អាខ្លាឯងក្នុងទឹកស្លាប់ទៅចុះ" ។ ខ្លារឹតតែភ័យតក់ស្លុតខ្លាំងទៅទៀត អង្វរតាពស់ព្រៃទៀត មាត់តែអង្វរ ជើងក៏លើកសំពះ ។ តាពស់ព្រៃមើលល្មមបានការហើយ ក៏ប្រាប់ខ្លាថា " មិនអីទេ ចាំអញរកវល្លិយ៉ាងធំចងអាខ្លាឯង " ។ ខ្លាឮដូច្នោះមានសេចក្តីត្រេកអរជាទីបំផុត តាពស់ព្រៃក៏បង្គាប់ឲ្យខ្លាដេកផ្ងារ ហើយយកវល្លិយ៉ាងធំមកចងជើងទាំង ៤ ផ្តោបគ្នា ហើយរែកព្យួរទៅនឹងចម្កាមឈើ ដែលមានកម្ពស់ល្មមយារដំបងវាយបាន ។ លុះតាពស់ព្រៃចងខ្លាព្យួរស្រេចហើយ ក៏ចេញទៅរកកាប់ដំបង ១ យ៉ាងធំ ដើម្បីយកមកសំពងខ្លា ដែលចងព្យួរនោះ ។ រីឯខ្លាកាលបើបានឃើញតាពស់ព្រៃទៅកាប់ឈើធ្វើជាដំបងធំយ៉ាងដូច្នោះ ក៏មានសេចក្តីសង្ស័យ ហើយសួរទៅតាពស់ព្រៃថា: តា ៗ ! កាប់ឈើមកធ្វើអីហ្នឹង ។ តាពស់ព្រៃប្រាប់ទៅខ្លាវិញថា: "អញកាប់ឈើ យកមកធ្វើជាដងរែករែកវល្លិយកទៅផ្ទះ" លុះតាពស់ព្រៃ កាប់ឈើធ្វើជាដំបងរួចស្រេច ក៏កាន់ដើរចូលទៅវាយសំពងអាខ្លា តាំងពីថ្ងៃត្រង់រហូតដល់ព្រលប់បណ្តាលឲ្យបាក់ឆ្អឹងជំនីរខ្លា ដូចគេរួបទាំងសងខាង ដៃខំវាយសំពង មាត់ក៏ផ្ចាញ់ផ្ចាលថា: " ពះអាខ្លា ! អាឯងខាំកូនអញទៀត " ។ ខ្លាខំប្រឹងបម្រះ រើយ៉ាងណាក៏ពុំរួច វាយរួចតាពស់ព្រៃ រកសំរាមនិងឈើងាប់ យកមកគរដុតពីខាងក្រោម បណ្តាលឲ្យឆេះរោមខ្លា និងរលាកស្បែកដុំ ៗ ហើយឆេះរហូតទៅដល់ខ្សែ ដែលចងព្យួរនោះដាច់ធ្លាក់ខ្លាមកដល់ដី បម្រះរួច រត់ចូលព្រៃបាត់ទៅ ។ ចំណែកតាពស់ព្រៃក៏ត្រឡប់ទៅកាន់ទីលំនៅរបស់ខ្លួនវិញ បាននិយាយរ៉ាយរ៉ាប់ប្រាប់ប្រពន្ធគាត់ អំពីរឿងដែលគាត់បានវាយខ្លានោះ សព្វគ្រប់ហើយ ក៏នៅជាសុខជាមួយនឹងប្រពន្ធគាត់រហូតអស់ជីវិតរៀងខ្លួន ។

មកពីមានរឿងដូចបានសម្តែងមកនេះហើយ បានជាខ្លាសព្វថ្ងៃ មានលក្ខណៈប្លែកពីសត្វទាំងពួង ៣ យ៉ាង

១- ឆ្អឹងជំនីរខ្លាកាលណាវាសំឡបទៅ ឃើញរាងបាក់រួបចូលគ្នា

២- សត្វខ្លាសព្វថ្ងៃនេះវាបន់ក្នុង ១ ថ្ងៃ ៧ ដង កុំឲ្យជួបនឹងមនុស្សយើង ព្រោះវាខ្លាចមនុស្ស តាំងពីតាពស់ព្រៃ ចងវាសំពងមក ។
៣- ខ្លាមានសម្បុរវាក្រវេមក្រវាម មកពីតាពស់ព្រៃដុតភ្លើងឆេះពោលនោះឯង ។